Theology on the Web.org.uk

Making Biblical Scholarship Accessible

This document was supplied for free educational purposes. Unless it is in the public domain, it may not be sold for profit or hosted on a webserver without the permission of the copyright holder.

If you find it of help to you and would like to support the ministry of Theology on the Web, please consider using the links below:

Buy me a coffee https://www.buymeacoffee.com/theology

PATREON https://patreon.com/theologyontheweb

PayPal https://paypal.me/robbradshaw

---

A table of contents for *Honeycomb* can be found here:

https://biblicalstudies.org.uk/articles_honeycomb.php

HONEYCOMB 5/1 (October 2004): 1–4



# Glorifying the Creator with our Creativity

*Gioia MICHELOTTI and Noren Vann KIM*

In the beginning, the one true God spoke a command that arose from his limitless imagination. Planet Earth was formed to spin gracefully through outer space in the company of myriads of mysterious heavenly bodies. This aerial ballet of stars, suns, planets, and moons has been performing ever since, through eons of time, and in galaxies vast and inaccessible. The most powerful telescopes on Earth or from space have caught only glimpses of their majestic processionals, which continue to proclaim the glory of their Maker.

Also in the beginning, this First Great Artist spoke another command, and a collage of life forms began to multiply upon Planet Earth, populating her fields, skies, and seas. Fantastic creations appeared, each patterned after a unique design—painted with vibrant colors, sculpted with varied textures, choreographed with rhythmic movements, accompanied by musical sounds, imbued with tantalizing aromas and tastes—all works of art without equal.

And God gloried in each of his creations, exclaiming that everything was very good. But his greatest masterpiece was yet to come—the creation of man and woman.

The first man was called Adam, not created by an impersonal command like God's previous creations. Instead, Adam

was intimately and painstakingly formed from the dust of his earthly home. He was, amazingly, designed in the image of God himself. And, finally, Adam was brought to life by the gentle breath of his loving Creator.

The one true God invited Adam to be co-creator with him. Not in the sense of being equal with God in his primary work of creation, but rather by fulfilling God's purposes for man's creation—to be a reflection of God's image and to give glory to God through the secondary channel of human creativity.

At first, Adam was commissioned to cultivate and keep the Garden of Eden, mankind's first home, making it a place of beauty. Then Adam was allowed to choose creative names for the special animals and birds created by God. Through all of this, God was causing Adam to realize his need for a companion like himself to help accomplish all this artistic work. And then God created the first woman, Eve, from the body of Adam, marrying them to each other as partners in God's appointed task.

This beautiful story is recorded in the first two chapters of Genesis, the first book of the Bible. But in the third chapter, we read about how evil entered the hearts of Adam and Eve. Satan, God's enemy, tempted them to disobey God's one negative command—not to eat the fruit of the Tree of the Knowledge of Good and Evil.

Because of this first sin, God's good creation began to be corrupted. The rest of the Bible describes how sin has continued to influence descendents of Adam and Eve throughout the ages, causing them to worship their artistic creations as idols, or compelling them to use their artistic gifts to glorify themselves or to serve Satan and his evil spirits.

But the One True God did not leave his creation without hope. Right in the middle of the sad story about the beginning of sin, God promised that He would one day send a savior to destroy Satan's corrupting work.[1] That promised savior is none other than Jesus Christ, God's only son!

Jesus Christ came from heaven to live a perfect life for us, to die on the cross to pay for our sins, and to rise from the dead to

---

[1]Gen 3:15.

reign forever at the right hand of God the Father in heaven. All who confess their sins and believe in Jesus, as Savior and Lord will be cleansed of their sin, filled with God's Holy Spirit, and saved from eternal punishment. It is up to us to receive or reject this priceless gift of salvation.

Jesus Christ was with God the Father creating all things in the beginning.[2] At his own appointed time in history, he came to reclaim for himself all the creation that mankind's sin had corrupted.[3] And mankind's artistic gifts are among the things that are being cleansed and reclaimed for God through Jesus Christ.

The Apostle Paul writes, "For everything created by God is good, and nothing is to be rejected, if it is received with gratitude; for it is sanctified by means of the word of God and prayer."[4] People are created by God, along with all of their creative gifts—here proclaimed "good" according to God's original design.

So, again, it is really up to us. We may choose to use art for sinful purposes, as the worshipers of the golden calf did.[5] They blatantly disobeyed God's command against worshipping idols.[6] Or we may choose to use art to glorify God, as those same people did when they skillfully fashioned the tabernacle in the wilderness, this time carefully following God's instructions.[7] There is also a third choice. Because of sinful artistic expressions in the world around them, some Christians reject most art forms as unsuitable for use in serving God. But this choice overlooks the many divine affirmations of sanctified art recorded in the Bible. And it also shrinks back from obeying clear scriptural commands, such as "Praise Him with timbrel and dancing."[8]

The Hebrew words *māḥôl* and *mᵉḥôlâ* are used to describe both sinful and sanctified dance.[9] The scripture writers do not

---

[2]Jn 1.
[3]Col 1.
[4]1 Tim 4:4–5NASB.
[5]Ex 32.
[6]Ex 20.
[7]Ex 25–31.
[8]Ps 150:4NASB.
[9]See Ex 32:19 for the former; Ex 15:20; Ps 149; 150 for the latter.

assign any inherent morality to the act of dancing itself. Therefore, the purpose for its use and the heart intention of the dancer renders the dancing acceptable or not before God. The same reasoning would apply to every art form.

The Bible is filled with references to art that has been sanctified to bring glory to God. Music, singing, and dancing are often included together.[10] Visual art is highlighted in descriptions of both the wilderness tabernacle and the temple in Jerusalem.[11]

Drama was often used by Hebrew prophets to convey messages from God.[12] The entire book of Job seems to be constructed in the form of a play. And much of the Bible is written in poetry, especially the Psalms and the Song of Solomon. The stories of Esther and Ruth are masterpieces of Hebrew literature. And the parables of Jesus illustrate yet another unique literary genre.

So, let us embrace these examples from the Bible. Let us also join with one another as co-creators with the Creator of the universe, bringing beauty and meaning to life on Planet Earth, as we reflect the image of God and glorify the creator through our creativity.

---

[10]Ex 15; 2 Sam 6; Ps 149; 150.

[11]Ex 25–31 for the tabernacle; 1 Ki 6–7 for the temple.

[12]E.g., Ezek 4–5.

សំណុំឆឹកឃ្មុំ ៥/១ (តុលា ២០០៤)៖ ៥-១១



# ការលើកតម្កើងព្រះអាទិករដោយប្រើប្រឌិតញ្ញាណរបស់យើង

*អ្នកស្រី មីតើឡូទី ចអ៊ីយ៉ា*
*អ្នកស្រី គីមវ៉ាន់ ណូរ៉េន*

កាលពីដើមដំបូងឡើយ ព្រះដ៏ពិតតែមួយមានបន្ទូលផុសចេញមកព្រះប្រាជ្ញាញាណដែលគ្មានដែនកំណត់របស់ព្រះអង្គ ។ ពិភពផែនដីបានកកើតឡើងដោយវិលជុំវិញខ្លួនឯងដ៏ស្រស់ត្រកាលនៅនាកណ្ដាលលំហអាកាសដែលអមដោយផែនភពអាថ៌កំបាំងច្រើនឥតគណនានៃចក្រវាឡដ៏ត្រកាលជាច្រើនទៀត។ ដួងព្រះអាទិត្យ ព្រះច័ន្ទ និង ហ្វូងតារាប្រៀបដូចជាក្រុមរបាំទាំងសល់សែន ត្រេចចរតាមគន្លងតារាវិថីកាត់តាមកញ្ចុំផ្កាយដ៏សែនក្រាស់ និងស្ទើរតែមិនអាចឆ្លងបានដែលមានរយៈពេលដ៏យូរលង់ណាស់មកហើយនោះ។ កែវឆ្លុះដែលមានកម្លាំងខ្លាំងបំផុតទាំងឡាយដែលគេតាំងនៅលើផែនដី ឬ នៅលើលំហអាកាសអាចគ្រាន់តែចាប់យករូបភាពតិចតួចប៉ុណ្ណោះពីគោចរដ៏រុងរឿងរបស់ហ្វូងផ្កាយទាំងនោះ ដែលកំពុងតែបន្តប្រកាសពីសិរីរុងរឿងដល់ម្ចាស់ដែលបានបង្កើតគេមកនោះ ។

នៅដើមដំបូងនោះដែរ ព្រះអាទិករដ៏ជាមហាវិចិត្រករដំបូងគេមានព្រះបន្ទូលបញ្ជាមួយព្រះឱស្ឋទៀតដែរឲ្យជីវិតទាំងឡាយគ្រប់ប្រភេទឲ្យបង្កើតពូជ

ជាពហុគុណាឡើងឲ្យបានពាសពេលលើភពផែនដីនេះទាំងនៅទីវាលផ្ទៃនភាល័យនិងទាំងក្នុងផ្ទៃមហាសាគរផង ។ ការកកើតនៃរបស់សព្វសារពើដ៏ល្អប្រណិតអស្ចារ្យផុសឡើងជារូបរាងដោយឡែកៗពីគ្នា តាមគម្រោងដែលព្រះអង្គគ្រោងទុកជាស្រេចមានពណ៌ចំរុះរស់រវើក មានក្បាច់រចនាទៅតាមប្រភេទរៀងខ្លួនប្រកបដោយនាដសាស្ត្រស៊ីចង្វាក់គ្នានឹងចលនាទាំងឡាយលាយឡំសូរសៀងនៃដូរ្យតន្ត្រីធម្មជាតិពោរពេញដោយក្លិនពិដោរក្រអូបសាយលាយឡំនិង រសជាតិគួរជាទីត្រេកត្រអាលឥតឧបមា ទាំងនេះជាស្នាព្រះហស្តដែលប្រកបដោយសិល្បៈបញ្ជាក់ថាគ្មានស្នាដៃណាមកប្រៀបផ្ទឹមស្មើបាន ឡើយ ។

ព្រះជាម្ចាស់បានលើកតម្កើងរបស់សព្វសារពើដែលស្នាព្រះហស្តរបស់ព្រះអង្គ ដោយទតឃើញថាគ្រប់យ៉ាងទាំងគឺល្អប្រពៃហើយ ។ ប៉ុន្តែស្នាព្រះហស្តដ៏ឆ្នើមរបស់ព្រះអង្គមិនទាន់បានសម្រេចនៅឡើយទេ គឺជាការបង្កើតមនុស្សប្រុសនិងមនុស្សស្រី។

មនុស្សដំបូងគេបង្អស់នោះឈ្មោះអាដាមព្រះអង្គមិនបានបង្កើតមនុស្សដូចជារបស់សព្វសារពើដែលទ្រង់បានបង្កើតមកមុនៗនោះទេ ។ តែផ្ទុយទៅវិញ ព្រះអង្គបានបង្កើតអាដាមមកដោយយកព្រះហឫទ័យទុកដាក់និងចំណាយពេលពូតផ្គុំពីធូលីដីដែលជាលំនៅរបស់អាដាម ។ ការដែលគួរឲ្យអស្ចារ្យនោះគឺព្រះអង្គបានបង្កើតអាដាមនៅក្នុងសណ្ឋាននៃរូបអង្គទ្រង់ ។ ទីបំផុតអាដាមមានជីវិតរស់ឡើងដោយសារព្រះជាម្ចាស់ជាព្រះអាទិករដែលប្រកបដោយសេចក្ដីស្រឡាញ់បានផ្ដល់ខ្យល់ដង្ហើមឲ្យគាត់ ។

ព្រះពិតតែមួយបានបបួលអាដាមឲ្យធ្វើជាសហអាទិករជាមួយព្រះអង្គ ។ មិនមែនមានន័យថា អាដាមមានតម្លៃស្មើនឹងព្រះជាម្ចាស់នោះឡើយ តែអាដាមជាអ្នកបំពេញតាមគោលបំណងរបស់ព្រះអង្គដែលបង្កើតមនុស្សមកក្នុងរូបអង្គទ្រង់ដើម្បីថ្វាយសិរីរុងរឿងដល់ព្រះជាម្ចាស់ប្រកបដោយប្រឌិតញាណរបស់មនុស្ស ។

ដំបូងព្រះជាម្ចាស់ផ្ដល់ការងារឲ្យអាដាមមើលការខុសត្រូវក្នុងការដាំដុះ និងមើលថែទាំសួនអេដែន ដែលជាលំនៅឋានដំបូងរបស់មនុស្សជាតិ ហើយធ្វើឲ្យកន្លែងនោះមានសោភ័ណភាពស្រស់បំព្រង ។ បន្ទាប់មកព្រះជាម្ចាស់អនុញ្ញាតឲ្យអាដាមជ្រើសរើសដាក់ឈ្មោះដល់សត្វទាំងឡាយ និង បក្សាបក្សី ដែលព្រះអង្គបានបង្កើតមក ។ តាមរយៈការងារទាំងនេះធ្វើឲ្យអាដាមយល់ឃើញថាគាត់ត្រូវការគូកនម្នាក់ដែលមានលក្ខណៈដូចជារូបគាត់ដើម្បីជួយបំពេញការងារដែលមានលក្ខណៈជាសិល្បៈ ។ ពេលនោះព្រះជាម្ចាស់បានបង្កើតមនុស្សស្រីដំបូងឈ្មោះអេវ៉ា ចេញពីរូបរាងរបស់អាដាម ហើយព្រះអង្គបានរៀបការគេទាំងពីរឲ្យធ្វើ ជាដៃគូជីវិតក្នុងការងារដែលព្រះជាម្ចាស់បំរុងទុកឲ្យគេធ្វើ ។

រឿងដ៏ស្រស់បំព្រងនេះបានកត់ទុកនៅក្នុងពីរជំពូកដំបូងនៃកណ្ឌគម្ពីរលោកុប្បត្តិដែលជាកណ្ឌគម្ពីរដំបូងនៅក្នុងព្រះគម្ពីរ ។ ប៉ុន្តែនៅជំពូកទីបី យើងអានពីរបៀបដែលការអាក្រក់បានចូលមកក្នុងដួងចិត្តរបស់ អាដាម និង អេវ៉ា ។ សាតាំងដែលជាខ្មាំងសត្រូវរបស់ព្រះបានល្បួងអ្នកទាំងពីរមិនស្ដាប់បង្គាប់របស់ព្រះជាម្ចាស់ថាហាមទទួលទានផ្លែដើមដឹងខុសដឹងត្រូវ ។

ដោយសារតែអំពើបាបដំបូងនេះហើយស្នាព្រះហស្ដដ៏ល្អប្រពៃទាំងអស់ចាប់ផ្ដើមក្លាយទៅជាពុករលួយ ។ នៅក្នុងកណ្ឌគម្ពីរទាំងមូលបានរៀបរាប់ពីរបៀបដែលអំពើបាបបន្តមានឥទ្ធិពលលើពូជពង្សរបស់អាដាម និង អេវ៉ាតាំងពីដើមរៀងមក ដែលបណ្ដាលឲ្យគេបែរទៅថ្វាយបង្គំរូបឆ្លាក់ផ្សេងៗធ្វើជាព្រះរបស់ខ្លួន ឬ បង្ខំឲ្យគេប្រើជំនាញផ្នែកសិល្បៈដ៏ប្រសើរដែលជាអំណោយទានមកពីព្រះដើម្បីតំកើងខ្លួនឯង ឬទៅបំរើសាតាំងនិងពួកវិញ្ញាណអាក្រក់របស់វាទៅវិញ ។

តែព្រះពិតតែមួយមិនបានទុកចោលស្នាព្រះហស្ដដ៏ល្អរបស់ព្រះអង្គឲ្យគ្មានសេចក្ដីសង្ឃឹមឡើយ ។ នៅចំកណ្ដាលរឿងទុក្ខព្រួយនៃអំពើបាបដំបូង

ព្រះជាម្ចាស់បានសន្យាថាថ្ងៃមួយព្រះអង្គនឹងបញ្ជូនព្រះអង្គសង្គ្រោះមួយអង្គ ឲ្យយាងមកបំផ្លាញផែនការអាក្រក់របស់សាតាំង[១]។ ព្រះអង្គសង្គ្រោះដែលព្រះជាម្ចាស់បានសន្យាផ្តល់ឲ្យយើងនោះ គឺគ្មាននរណាក្រៅពីព្រះយេស៊ូគ្រីស្ត ជាព្រះរាជបុត្រតែមួយរបស់ព្រះអង្គឡើយ !

ព្រះយេស៊ូគ្រីស្តបានយាងពីស្ថានសួគ៌ចុះមករស់នៅជាជីវិតដ៏ល្អឥតខ្ចោះ សំរាប់យើងរាល់គ្នា ដើម្បីសុគតនៅលើឈើឆ្កាងសំរាប់លោះបាបយើង ហើយរស់ពីសុគតឡើងវិញគង់នៅសោយរាជ្យអស់កល្បជានិច្ចនៅខាងស្តាំព្រះបិតា នៅស្ថានសួគ៌ ។ មនុស្សទាំងអស់ដែលបានលន់តួអំពើបាបរបស់ខ្លួនហើយ ទទួលជឿព្រះយេស៊ូទុកជាព្រះអង្គសង្គ្រោះ និង ព្រះអម្ចាស់នោះនឹងបានស្អាតពីអំពើបាបរបស់ខ្លួនបានពេញដោយព្រះវិញ្ញាណបរិសុទ្ធ ហើយបានសង្គ្រោះឲ្យរួចពីទោសទណ្ឌកម្មដ៏អស់កល្ប ។ ចំពោះការនេះគឺអាស្រ័យលើយើងទាំងអស់គ្នាព្រមទទួលឬមិនព្រមទទួលនូវអំណោយនៃការសង្គ្រោះដ៏មានតម្លៃកាត់ថ្លៃមិនបាននោះ ។

ព្រះយេស៊ូគ្រីស្តគង់នៅជាមួយព្រះជាម្ចាស់ជាព្រះបិតាដែលបានបង្កើតរបស់សព្វសារពើតាំងពីដើមមកនោះ[២] ។ នៅក្នុងពេលដែលព្រះអង្គបានកំណត់ទុកដោយព្រះអង្គផ្ទាល់នៅក្នុងប្រវត្តិសាស្ត្រព្រះអង្គបាន យាងមកដើម្បីប្រកាសដោយអង្គទ្រង់ផ្ទាល់ពីអំពើបាបរបស់មនុស្សជាតិ ដែលបានធ្វើឲ្យខូចទំនាក់ទំនងរបស់ព្រះអង្គ និង មនុស្ស[៣] ។ អំណោយទានផ្នែកសិល្បៈរបស់មនុស្សជាតិជារបស់មួយក្នុងចំណោមរបស់ទាំងឡាយដែលព្រះជាម្ចាស់បានលាងសំអាត និងព្រះអង្គបានប្រកាសទាមទារយកមកជារបស់ព្រះជាម្ចាស់វិញតាមរយៈការងាររបស់ព្រះយេស៊ូគ្រីស្ត ។

---

[១] *លោកុប្បត្តិ ៣:១៥*

[២] *យ៉ូហាន ១*

[៣] *កូឡុស ១*

លោកសាវ័កប៉ុលបានសរសេរថា៖ “ ដ្បិតសត្វទាំងអស់ដែលព្រះទ្រង់បង្កើតមកនោះសុទ្ធតែល្អ ហើយមិនត្រូវចោលមួយឡើយឲ្យគ្រាន់តែទទួលដោយអរព្រះគុណប៉ុណ្ណោះ ដ្បិតបានញែកជាបរិសុទ្ធដោយសារព្រះបន្ទូលហើយសេចក្តីអធិស្ឋាន”[៤]។ ព្រះជាម្ចាស់ជាអ្នកបង្កើតមនុស្សមកដោយមានអំណោយទាននៃគំនិតច្នៃប្រឌិតដ៏ល្អប្រពៃស្របតាមផែនការដំបូងដែលព្រះអង្គបានគ្រោងទុក ។

ដូច្នេះគឺអាស្រ័យលើយើង ។ យើងអាចប្រើប្រាស់សិល្បៈ សំរាប់បំរើក្នុងគោលបំណងអាក្រក់នៃអំពើបាបដូចជាពួកអ្នកថ្វាយបង្គំរូបគោមាស[៥] ។ ពួកគេមិនបានស្តាប់បង្គាប់ព្រះជាម្ចាស់ដោយការប្រឆាំងនឹងព្រះរាជបញ្ជារបស់ព្រះអង្គចំពោះការថ្វាយបង្គំរូបព្រះបដិមាករ[៦]។ ឬក៏យើងអាចជ្រើសយកសិល្បៈ មកប្រើដើម្បីសរសើរតម្កើងព្រះជាម្ចាស់ដូចពួកអ្នកដែល បានតុបតែងរោងឧបោសថយ៉ាងស្ទាត់ជំនាញ កាលនៅក្នុងវាលរហោស្ថានពេលនោះគេបានធ្វើតាមសេចក្តីបង្រៀនរបស់ព្រះជាម្ចាស់យ៉ាងប្រុងប្រយ័ត្ន[៧] ។ មានជម្រើសទីបីមួយទៀត ។ ដោយសារតែការស្តែងចេញនូវសិល្បៈដែលប្រកបដោយអំពើបាបនៅក្នុងពិភពលោកដែលនៅជុំវិញខ្លួនគេមានគ្រីស្តបរិស័ទខ្លះបដិសេធយកទម្រង់នៃសិល្បៈជាច្រើនដែលមិនសមរម្យក្នុងការបំរើព្រះជាម្ចាស់ ។ ប៉ុន្តែជម្រើសនេះបានមើលរំលងចំពោះការអះអាងរបស់ព្រះជាម្ចាស់ដែលទាក់ទងនឹងសិល្បៈនៃការគោរពបូជាដែលកត់ទុកនៅក្នុងព្រះគម្ពីរ ។ ហើយការនេះថែមទាំងបង្រ្កមពីការគោរពតាមបទគម្ពីរដែលបានចែងថា “ ចូរសរសើរទ្រង់ដោយវាយក្រាប់ ហើយលោតកញ្ឆេង” [៨] ។

---

[៤] *១ ធីម៉ូថេ ៤:៤-៥*

[៥] *និក្ខមនំ ៣២*

[៦] *និក្ខមនំ ២០*

[៧] *និក្ខមនំ ២៥-៣១*

ពាក្យនៅក្នុងភាសាហេព្រើរ *ម៉ាហុល* និង *មេហុលឡា* គេប្រើសំរាប់ពណ៌នាទាំងរបាំដែលប្រកបដោយអំពើបាប និងដោយគោរពបូជា[៩] ។ អ្នកនិពន្ធមិនបានគូសបញ្ជាក់ពីសីលធម៌នៃសកម្មភាពរបស់របាំឡើយ ។ ហេតុដូច្នេះគោលបំណងនៃការប្រើសិល្បៈ និងបំណងចិត្តរបស់អ្នករបាំបង្ហាញថារបាំនោះអាចទទួលបាន និង មិនអាចទទួលយកបានចំពោះព្រះជាម្ចាស់ ។ ហេតុផលដូចគ្នាសំរាប់ទំរង់នៃសិល្បៈទាំងអស់ ។

ព្រះគម្ពីរមានខយោងជាច្រើនទាក់ទងនឹងសិល្បៈដែលគេប្រើសំរាប់ថ្វាយសិរីរុងរឿងដល់ព្រះជាម្ចាស់ ។ តន្ត្រី ចំរៀង និង របាំជារឿយៗតែងតែនៅជាប់ជាមួយគ្នា[១០]។ សិល្បៈដែលយើងមើលឃើញនោះបានពណ៌នាទាំងក្នុងទីសក្ការៈនៅវាលរហោស្ថាន និង ទាំងទីក្រុងយេរូសាឡឹម[១១] ។

ល្ខោនគេតែងយកមកប្រើនៅក្នុងសម័យហោរាហេព្រើរ ដើម្បីបញ្ជូនការសំដែងព្រះរាជសាររបស់ព្រះជាម្ចាស់[១២]។ នៅក្នុងកណ្ឌគម្ពីរយ៉ូបទាំងមូលហាក់បីដូចជាតែងឡើងជាទំរង់នៃការសំដែងល្ខោន ។ បទគម្ពីរភាគច្រើនគេសរសេរឡើងជាបែបបទកំណាព្យ ជាពិសេសកណ្ឌគម្ពីរទំនុកតម្កើង និង ចំរៀងសាឡូម៉ូន ។ រឿងរបស់អេសធើ និង នាងរស់ជាជំនាញអក្សរសិល្ប៍ហេព្រើរ ។ រីឯរឿងប្រៀបប្រដូចរបស់ព្រះយេស៊ូបង្ហាញពីលក្ខណៈពិសេសនៃ អក្សរសិល្ប៍មួយបែបទៀត។

---

[៨] *ទំនុកតម្កើង ១៥០:៤*

[៩] *សូមមើលនិក្ខមនំ ៣២:១៩ សំរាប់ពេលមុនៗ និក្ខមនំ ១៥:២០ ទំនុកតម្កើង១៤៩; ១៥០ សំរាប់ពេលក្រោយៗ។*

[១០] *និក្ខមនំ ១៥ ; ២ សាំយូអែល ៦ ;ទំនុកតម្កើង ១៤៩ ; ១៥០*

[១១] *និក្ខមនំ ២៥-៣១ សំរាប់រោងឧបោសថ; ១ពង្សាវតារ ៦-៧ សំរាប់ព្រះវិហារនៅក្នុងក្រុងយេរូសាឡឹម ។*

[១២] *ឧទាហរណ៍ អេសេគាល ៤-៥*

ដូច្នេះសូមយើងយកគំរូទាំងអស់នេះពីក្នុងព្រះគម្ពីរមកប្រើ ។ ហើយសូមឲ្យយើងរួមគ្នាជាសហអាទិករជាមួយព្រះអាទិករលើសាកលលោកនេះ ដោយនាំមកនូវសោភ័ណភាព និងអត្ថន័យដល់ជីវិតដែលនៅលើផែនដី នៅពេលដែលយើងសញ្ជឹងគិតអំពីរូបអង្គព្រះជាម្ចាស់និងថ្វាយសិរីរុងរឿងដល់ព្រះអាទិករតាមរយៈគំនិតច្នៃប្រឌិតរបស់យើង ។